មិថុនា ២០១៧

# ការពិត និងតួលេខ #៣២

# ការឃ្លាំមើលសកម្មភាពតស៊ូមតិរបស់សហគមន៍ក្នុងរាជធានីភ្នំពេញ




សមាគមធាងត្នោត
Sahmakum Teang Tnaut, a Cambodian Urban NGO

សមាគមធាងត្នោត

Sahmakum Teang Tnaut. a Cambodian Urban NGO

## ការពិត និងតួលេខ #៣២

**ខែមិថុនា ឆ្នាំ២០១៧**

ឯកសារបោះពុម្ពផ្សាយស្តីអំពីបញ្ហាក្នុងទីក្រុង

ដោយអង្គការសមាគមធាងត្នោត (STT)

# ការឃ្លាំមើលសកម្មភាពតស៊ូមតិ
# របស់សហគមន៍ក្នុងរាជធានីភ្នំពេញ

# ការឃ្លាំមើល សកម្មភាពតស៊ូមតិ របស់សហគមន៍ក្នុង រាជធានីភ្នំពេញ

## ការពិត និងតួលេខ

*ខែមិថុនា ឆ្នាំ២០១៧*

ឯកសារបោះពុម្ពផ្សាយស្តីអំពីបញ្ហាក្នុងទីក្រុង
ដោយអង្គការសមាគមធាងត្នោត (STT)

សមាគមធាងត្នោត
Sahmakum Teang Tnaut. a Cambodian Urban NGO

# #៣២

## ទិដ្ឋភាពទូទៅ

រាជធានីភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័សដែលឃើញមានការវិនិយោគកើនឡើងយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។[1] ជាមួយនឹងអត្រាចំនួនប្រជាជនបច្ចុប្បន្នប្រមាណ១.៥ លាននាក់ក្នុងរាជធានីភ្នំពេញ[2] និងកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំប្រមាណ២.២% រវាងឆ្នាំ២០១៧ និង២០២៥[3]។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ លំនៅដ្ឋាន និងហាងទំនិញបានក្លាយជាចំណុចដ៏សំខាន់មួយសម្រាប់ទីក្រុងដែលជារាជធានីនៃប្រទេសកម្ពុជា។

ការអភិវឌ្ឍអាចនាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់ទីក្រុង និងប្រជាជនដែលរស់នៅក្នុងទីក្រុងនោះ ដូចជា ឱកាសការងារកាន់តែច្រើន ផលិតភាពកើនឡើង ភាពច្នៃប្រឌិត វិស័យអប់រំ និងសុខាភិបាលមានភាពល្អប្រសើរ និងចំណូលកាន់តែខ្ពស់ជាងមុន។ ប៉ុន្តែជារឿយៗ ការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញត្រូវបានគេមើលឃើញថាតែងតែមានការរំលោភលើ ឬសាងសង់ទាំងស្រុងក្នុងតំបន់ដែលប្រជាពលរដ្ឋកំពុងរស់នៅតែម្តង[4]។ ជាពិសេសក្នុងរយៈពេលខ្លីទៅមធ្យម តំបន់ក្រីក្រក្នុងរាជធានីភ្នំពេញជាញឹកញាប់តែងទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍដែលខ្វះខាតនូវការការពារសុវត្ថិភាពកម្មសិទ្ធដីធ្លី និងឱកាសទទួលបានសំណងសមរម្យនៅពេលមានការបណ្តេញចេញ[5]។

ជាការឆ្លើយតបចំពោះការរំលោភបំពានដោយសារការអភិវឌ្ឍមកលើសហគមន៍ក្រីក្រនានាក្នុងរាជធានីភ្នំពេញ សហគមន៍ទាំងនោះបានចេញមកធ្វើការតស៊ូមតិទាមទារឲ្យមានការគោរពសិទ្ធិដីធ្លីរបស់ពួកគេ។ ក្នុងចន្លោះឆ្នាំ២០១៣ និងឆ្នាំ២០១៦ អង្គការសមាគមធាងត្នោតបានឃ្លាំមើលសកម្មភាពតស៊ូមតិរបស់សហគមន៍ក្នុងរាជធានីភ្នំពេញ។ អង្គការសមាគមធាងត្នោតបានឃ្លាំមើលសកម្មភាពសហគមន៍បានចំនួន ២៩៣ដង ដែលក្នុងនោះ ១៤២ដង កើតឡើងពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងករណីសិក្សាសំខាន់ៗមួយចំនួនទៀតដែលត្រូវបានលើកយកមកសិក្សាវិភាគ និងបង្ហាញក្នុងរបាយការណ៍នេះ។




*សកម្មជនសហគមន៍ក្នុងទីក្រុង និងតាមបណ្ដាខេត្តនានាមកជួបជុំគ្នាដើម្បីប្រារព្ធទិវាលំនៅដ្ឋានពិភពលោក និងអ្នកដាក់ញត្តិអំពាវនាវឲ្យរដ្ឋាភិបាលគោរពសិទ្ធិលំនៅដ្ឋាននៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦។*
*ប្រភព៖  អង្គការសមាគមធាងត្នោត ឆ្នាំ២០១៦*

## សេចក្តីផ្តើម

ការរីកចម្រើនយ៉ាងលឿនក្នុងរាជធានីភ្នំពេញត្រូវបានមើលឃើញថា បានជំរុញឲ្យមានកំណើនតម្រូវការអគារសម្រាប់អគារមជ្ឈមណ្ឌលពាណិជ្ជកម្ម និងហាងទំនិញ ហើយការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងអគារស្នាក់នៅសម្រាប់កំណើនប្រជាជនចេះតែកើនឡើងដែរ។ ប៉ុន្តែនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនច្រើនកុះករដូចរាជធានីភ្នំពេញនេះ ដីទំនេរសម្រាប់ការសាងសង់មានចំនួនតិចណាស់ប្រសិនបើមិនរំលោភលើដីធ្លីដែលជាកម្មសិទ្ធិរបស់បុគ្គលណាម្នាក់។

កម្មសិទ្ធិដីធ្លីត្រូវបានលុបបំបាត់ក្នុងអំឡុងរបបខ្មែរក្រហម ហើយប័ណ្ណកម្មសិទ្ធិដីទាំងអស់ត្រូវបានបំផ្លាញ។ បន្ទាប់ពីរបបនេះបានដួលរលំ ការទទួលបានកម្មសិទ្ធិដីធ្លីគឺឈរលើមូលដ្ឋាន 'មកមុនបានមុន" ដោយសារប្រទេសកម្ពុជាមានភាពយឺតយ៉ាវនៃដំណើរការផ្តល់នូវរបបកម្មសិទ្ធិឯកជនលើដីធ្លីឡើងវិញ។ នៅក្នុងឆ្នាំ២០០១ ច្បាប់ភូមិបាលកម្ពុជាត្រូវបានអនុម័តដោយបង្កើតបានជាក្របខ័ណ្ឌសម្រាប់កម្មសិទ្ធិឯកជនលើដីធ្លី និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី។ ប៉ុន្តែទោះជាយ៉ាងណា ប្រព័ន្ធដែលមានលក្ខណៈមិនត្រឹមត្រូវ និងការភាន់ច្រឡំក្នុងដំណើរការដាក់ពាក្យស្នើសុំ និងទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនេះ[6]បានបណ្តាលឲ្យមានជម្លោះរវាងអាជ្ញាធរកម្ពុជា ក្រុមហ៊ុនឯកជន និងប្រជាពលរដ្ឋនៃសហគមន៍ដែលត្រូវបណ្តេញចេញសម្រាប់ការអភិវឌ្ឍ[7]។ ផលវិបាកនៃជម្លោះទាំងនេះនាំឲ្យសហគមន៍បន្តធ្វើសកម្មភាពនានា រួមមានការចុះហត្ថលេខាលើញត្តិតវ៉ា បាតុកម្ម និងការសំដែងការព្រួយបារម្ភតាមវេទិកានានាដូចជាតាមស្ថានីយ៍វិទ្យុក្នុងស្រុក និងតាមរយៈក្រុមពិភាក្សាផ្សេងៗជាដើម។

សកម្មភាព និងទិន្នន័យនៅក្នុងរបាយការណ៍នេះ ពិនិត្យមើលលើព្រឹត្តិការណ៍ទាំងនេះ តែក៏មានរួមបញ្ចូលផងដែរនូវសកម្មភាពតស៊ូមតិរបស់សហគមន៍ធ្វើឡើងដើម្បីតវ៉ាប្រឆាំងនឹងការជាប់ពន្ធនាគាររបស់សកម្មជនដែលបានប្រយុទ្ធប្រឆាំង និងបានបន្តប្រយុទ្ធប្រឆាំងដើម្បីទទួលបានលំនៅដ្ឋាន និងសំណងសមរម្យសម្រាប់គ្រួសារដែលត្រូវបានបណ្តេញចេញ។ សកម្មភាពភាគច្រើនរបស់សហគមន៍គឺជាការឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងរាជធានីភ្នំពេញ ប៉ុន្តែអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិបន្តរារាំងមិនឱ្យមានការចូលរួមក្នុងការតស៊ូមតិទាំងនោះ។ ក្នុងករណីជាច្រើនកន្លងមក កងកម្លាំងប៉ូលីសបានប្រើអំពើហិង្សាដើម្បីបញ្ឈប់ការតវ៉ាទាំងនោះ ប៉ុន្តែទាំងមជ្ឈដ្ឋានជាតិ និងអន្តរជាតិបានមើលឃើញថា កម្ពុជានៅតែបន្តរំលោភបំពានសិទ្ធិមនុស្សគួរឱ្យព្រួយបារម្ភ។[8]

របាយការណ៍ខាងក្រោមនេះនឹងបង្ហាញពីទិន្នន័យដែលប្រមូលបានដោយអង្គការសមាគមធាងត្នោត និងផ្តល់នូវការយល់ដឹងលើសកម្មភាពតស៊ូមតិសំខាន់ៗរបស់សហគមន៍ រួមបញ្ចូលទាំងការអភិវឌ្ឍតំបន់បឹងកក់ដ៏ចម្រូងចម្រាស និងសកម្មជនដីធ្លីដ៏លេចធ្លោដូចជាអ្នកស្រី ទេព វន្នី ជាដើម។

## វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

### ទិន្នន័យចម្បង

ទិន្នន័យដែលមានក្នុងរបាយការណ៍នេះ បានមកពីព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលឃ្លាំមើលរបស់អង្គការសមាគមធាងត្នោត និងបានមកពីរបាយការណ៍បន្តបន្ទាប់ដែលចេញដោយអង្គការសមាគមធាងត្នោត។

របាយការណ៍ទាំងនេះ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០១៣ ដល់ខែធ្នូ ឆ្នាំ២០១៦ សរុបចំនួន ២៩៣ របាយការណ៍ដែលក្នុងនោះ ១៤២ របាយការណ៍ ផ្តោតលើសកម្មភាពតស៊ូមតិពាក់ព័ន្ធនឹងបញ្ហាដីធ្លី។ របាយការណ៍ចំនួន១៥១ ផ្សេងទៀតផ្តោតលើសកម្មភាពដែលមិនពាក់ព័ន្ធនឹងដីធ្លី ដូចជា ការប្រារព្ធទិវាអន្តរជាតិនានារួមមាន ទិវាសិទ្ធិកុមារ ទិវាពលកម្ម រៀបចំថ្ងៃបោះឆ្នោតសម្រាប់តំណាងសហគមន៍ថ្មី និងពិធីជួបជុំបែបសាសនានានាជាដើម។ ព័ត៌មានដែលពាក់ព័ន្ធនឹងកាលបរិច្ឆេទ ទីកន្លែង និងមូលហេតុនៃការរៀបចំព្រឹត្តិការណ៍តែងតែត្រូវបានផ្តល់ឲ្យអង្គការសមាគមជាងត្នោតតាមរយៈទូរស័ព្ទ ឬផ្ញើសារបន្ទាន់ (ដូចជា Telegram ឬ WhatsApp) ពីសហគមន៍រៀបចំសកម្មភាពទាំងនោះ។ អង្គការដៃគូក្រៅរដ្ឋាភិបាល ក៏ទំនាក់ទំនងមកផ្តល់ព័ត៌មានផងដែរនៅពេលដែលមានគម្រោងរៀបចំសកម្មភាពតស៊ូមតិទាំងនោះ។

ក្នុងអំឡុងពេលការតវ៉ា និងការជួបជុំ អ្នកឃ្លាំមើលឈរពីចម្ងាយដើម្បីសង្កេតមើលស្ថានការណ៍ទូទៅដូចជា ចំនួនអ្នកចូលរួម និងវត្តមានរបស់អាជ្ញាធរជាដើម។ ការធ្វើបែបនេះគឺដើម្បីការពារអ្នកឃ្លាំមើលពីការកំណត់មុខសញ្ញាពីក្រុមអាជ្ញាធរផងដែរ។ អ្នកឃ្លាំមើលធ្លាប់ពាក់អាវកាក់សម្គាល់ ប៉ុន្តែចាប់តាំងពីដើមឆ្នាំ២០១៦ មក អាវកាក់សម្គាល់ទាំងនោះមិនត្រូវបានពាក់ជាទៀងទាត់ទេ ដោយសារអ្នកឃ្លាំមើលតែងតែត្រូវបានកំណត់មុខសញ្ញាដោយអាជ្ញាធរ និងមានពេលខ្លះ ទទួលរងការគំរាមកំហែងដោយផ្ទាល់មាត់ពីសំណាក់កងកម្លាំងរដ្ឋាភិបាលផងដែរ។ អ្នកឃ្លាំមើលសកម្មភាពរបស់សហគមន៍បានចូលទៅជិតក្រុមអ្នកតវ៉ា ប្រសិនបើសំណួរខ្លះត្រូវការសួរព័ត៌មានលម្អិតអំពីសកម្មភាពនោះ។ បច្ចុប្បន្ន ម៉ាស៊ីនថតត្រូវបានប្រើប្រាស់សម្រាប់ការថតរូប និងថតវីដេអូនៅពេលឃ្លាំមើលសកម្មភាពរបស់សហគមន៍។

## ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំត្រូវបានប្រើប្រាស់ដើម្បីវិភាគស៊ីជម្រៅបន្ថែមទៀតលើរបាយការណ៍ឃ្លាំមើលរបស់អង្គការសមាគមជាងត្នោត។ ព័ត៌មានទាំងនេះបានមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានា (ដូចជាសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (អាដហុក) សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងសន្ធិសញ្ញាអន្តរជាតិនានា (សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ)។

## ដែនកំណត់

ដោយសារតែអង្គការសមាគមជាងត្នោតជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលធនធាននៅមានកម្រិត ហេតុនេះហើយ អង្គការសមាគមជាងត្នោតមិនអាចឃ្លាំមើលគ្រប់សកម្មភាពរបស់សហគមន៍ទាំងអស់បានទេ។ ដូច្នេះ អង្គការសមាគមជាងត្នោតផ្តល់អាទិភាពចំពោះសកម្មភាពណាដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងលំនៅដ្ឋានក្នុងទីក្រុងដែលស្របនឹងទស្សនៈវិស័យ និងបេសកកម្មរបស់ខ្លួនប៉ុណ្ណោះ។ ដោយសារតែមូលហេតុនេះ ការរកឃើញក្នុងរបាយការណ៍នេះគឺផ្អែកទៅលើតែរបាយការណ៍ឃ្លាំមើលដែលត្រូវបានបញ្ចប់ និងផ្ទៀងផ្ទាត់រួចប៉ុណ្ណោះ។ បើទោះបីជាសកម្មភាពតស៊ូមតិផ្សេងៗទៀតរបស់សហគមន៍កើតឡើងក៏ដោយ ក៏សកម្មភាពទាំងនោះមិនត្រូវបានយកមកបញ្ចូលនៅក្នុងការស្រាវជ្រាវនេះដែរ។

## សិទ្ធិនៅកម្ពុជា

មានក្របខ័ណ្ឌច្បាប់សំខាន់ពីរនៅក្នុងប្រទេសកម្ពុជាដែលតែងតែត្រូវបានច្រានចោលដោយអាជ្ញាធរ ដែលជាញឹកញាប់នាំឲ្យសហគមន៍ធ្វើសកម្មភាពតស៊ូមតិដ៏ខ្លាំងក្លា។ ក្របខ័ណ្ឌទាំងនេះរួមមាន ច្បាប់ស្តីពីសិទ្ធិមនុស្ស និងសេរីភាពសមាគម និងការជួបប្រជុំដោយសន្តិវិធី។

បទប្បញ្ញត្តិដ៏សំខាន់ដែលចែងអំពីការគោរពសិទ្ធិមនុស្សនៅកម្ពុជា គឺកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលទទួលស្គាល់ក្របខ័ណ្ឌច្បាប់សម្រាប់ការពារសិទ្ធិរបស់ប្រជាជនកម្ពុជា ដូចជាសេរីភាពនៃការបញ្ចេញមតិ សេរីភាពសមាគម និងការប្រមូលផ្តុំដោយសន្តិវិធី។ បទប្បញ្ញត្តិនោះចែងថា"... ប្រទេសកម្ពុជាអនុវត្តន៍តាមកិច្ចព្រមព្រៀងនេះដើម្បីធានាឱ្យបាននូវការគោរព និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានក្នុងប្រទេសកម្ពុជា... និងដើម្បីគាំទ្រដល់សិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការអនុវត្តសកម្មភាពនានាដែលលើកកម្ពស់ដល់ការគោរព និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[9] "។

នៅក្នុងឆ្នាំ២០០៩ ប្រទេសកម្ពុជាបានដាក់បញ្ចូលសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធីទៅក្នុងច្បាប់ជាតិដោយចែងយ៉ាងច្បាស់ក្នុងមាត្រា៤ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីដែលមានខ្លឹមសារថា "ការប្រមូលផ្តុំគ្នាដោយសន្តិវិធីសំដៅដល់ការប្រមូលផ្តុំ ឬការដង្ហែក្បួនដោយមនុស្សមួយក្រុមដើម្បីទាមទារ តវ៉ា ឬសំដែងនូវមនោសញ្ចេតនា គំនិត ឬឆន្ទៈរបស់ក្រុមខ្លួនជាសាធារណៈតាមរូបភាព ឬមធ្យោបាយផ្សេងៗដោយសន្តិវិធី"[10]។ ច្បាប់នេះត្រូវបានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិនានាដែលក្នុងនោះមានដូចជាមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[11] និងមាត្រា២១ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[12]។

សេរីភាពបញ្ចេញមតិ សេរីភាពនៃការបង្កើតសមាគម និងសេរីភាពនៃការប្រមូលផ្តុំគ្នាដោយសន្តិវិធី (ដែលជាសេរីភាពមូលដ្ឋានទទួលស្គាល់ដោយអាជ្ញាធរកម្ពុជា និងបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជាដូចដែលមានចែងក្នុងមាត្រា៣១ មាត្រា៤១ និងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងឆ្នាំ២០០៧) "ចែងថា មនុស្សគ្រប់រូបមានសិទ្ធិផ្ទាល់ខ្លួន និងចូលរួមសមាគមជាមួយបុគ្គលផ្សេងទៀតទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិក្នុងការជួបប្រជុំគ្នា ឬប្រមូលផ្តុំគ្នាដោយសន្តិវិធី"[13]។ ប៉ុន្តែការជួបប្រជុំទាំងនេះតែងទទួលរងការយាយីដោយហិង្សាពីអាជ្ញាធរមានសមត្ថកិច្ចដោយចោទប្រកាន់ថាធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម។ របាយការណ៍សង្ខេបដែលចេញផ្សាយដោយអង្គការលីកាដូក្នុងឆ្នាំ២០០៧ លើកឡើងថាអំពីអំពើហិង្សាទាំងនេះ ជាការឆ្លើយតបរបស់អាជ្ញាធរចំពោះការតវ៉ាដោយសន្តិវិធី" ហើយការបង្ក្រាបនេះកំពុងធ្វើឡើងតាមទំនើងចិត្តប្រឆាំងទៅនឹងការធ្វើបាតុកម្ម តាមរយៈការប្រើហិង្សាបំបែកក្រុមអ្នកតវ៉ាដោយសន្តិវិធី និងចាប់ខ្លួនអ្នកចូលរួមក្នុងការប្រមូលផ្តុំគ្នាដោយស្របច្បាប់ផងដែរ"[14]។

បទប្បញ្ញត្តិបន្ថែមត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ហើយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មានរបស់ខ្លួនថា "ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី... "ដែលជាបញ្ញត្តិប្រកបដោយ "ភាពចម្រូងចម្រាស និងការភាន់ច្រឡំ "គឺការបង្កើតសួនប្រជាធិបតេយ្យ"[15]។ គេសន្មតថាសេចក្តីបន្ថែមក្នុងច្បាប់នេះចែងថា ការធ្វើបាតុកម្មទាំងអស់ត្រូវតែធ្វើនៅទីកន្លែងមួយដែលបានកំណត់គឺសួនប្រជាធិបតេយ្យ ប៉ុន្តែបើតាមច្បាប់នាពេលបច្ចុប្បន្ននេះ សួនប្រជាធិបតេយ្យនេះគឺជាកន្លែងដែលអាចធ្វើបាតុកម្មបាន ប៉ុន្តែ មិនមែនមានន័យថារាល់ការធ្វើបាតុកម្មនានាសុទ្ធតែត្រូវធ្វើនៅកន្លែងនោះទេ។

មូលហេតុដែលនាំឲ្យមានធ្វើសកម្មភាពតស៊ូមតិរបស់សហគមន៍ក្នុងរាជធានីភ្នំពេញ ដែលឃ្លាំមើលដោយអង្គការសមាគមផាងត្នោត គឺអាជ្ញាធរមិនបានគោរពទៅតាមច្បាប់នានាដែលបានលើកឡើងខាងលើនោះទេ ដោយប្រជាពលរដ្ឋចោទប្រកាន់ថាមានការប្រព្រឹត្តអំពើពុករលួយក្នុងប្រព័ន្ធតុលាការ ដែលការនេះហាក់ដូចជាមានឥទ្ធិពលទៅលើអំណាចនៃច្បាប់ទៅទៀត។ ការបណ្តេញចេញដោយបង្ខំបានក្លាយជាចំណុចដែលត្រូវបានឃ្លាំមើលដោយអង្គការសិទ្ធិមនុស្សទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ[16]។ ការបណ្តេញចេញនេះកើតមានឡើងជាដដែលៗយ៉ាងច្រើនក្នុងរាជធានីភ្នំពេញ។ ក្នុងនាមជាសមាជិកនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កម្ពុជាមានកាតព្វកិច្ច "ក្រោមសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យដោយមិនត្រូវបណ្តេញប្រជាពលរដ្ឋរបស់ខ្លួនដោយបង្ខំចេញពីលំនៅដ្ឋានឡើយ"[17]។ ប៉ុន្តែអង្គការសមាគមផាងត្នោតរកឃើញថា ក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៦ មានប្រជាពលរដ្ឋកម្ពុជាជាង ២៩.៧០០ គ្រួសារក្នុងរាជធានីភ្នំពេញត្រូវបានណ្តេញចេញ ឬផ្លាស់ទីលំនៅដោយសារតែការអភិវឌ្ឍទីក្រុង[18]។

ជាការកត់សម្គាល់ អាជ្ញាធរបានប្រើប្រាស់ការរំលោភសិទ្ធិមនុស្សនេះដើម្បីបំបិទមាត់សកម្មជនសិទ្ធិមនុស្ស ដែលប្រការនេះត្រូវបានអង្គការលើកលែងទោសអន្តរជាតិលើកឡើងថា "បុគ្គល និងក្រុមអ្នកមានអំណាចដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីនៅកម្ពុជាបាននិងកំពុងតែប្រើអំណាចរបស់ខ្លួនកាន់តែខ្លាំងឡើងៗដើម្បីបំបិទមាត់ក្រុមជំទាស់តាមរយៈការប្រើប្រាស់ប្រព័ន្ធតុលាការ[19]។

## ការរកឃើញ

ផ្នែកខាងក្រោមនេះ បង្ហាញពីការវិភាគលើរបាយការណ៍ឃ្លាំមើលរបស់អង្គការសមាគមផាងត្នោត។ ការវិភាគនេះផ្តោតលើចំនួនរបាយការណ៍ ដើម្បីកំណត់ថាតើនៅពេលណាដែលសកម្មភាពតស៊ូមតិរបស់សហគមន៍បានធ្វើឡើងច្រើនបំផុត។ ហេតុដូច្នេះ យើងស្វែងយល់និងដឹងពីព្រឹត្តិការណ៍សំខាន់ៗនានាជាមុនសិន ដើម្បីឱ្យមានការសន្និដ្ឋានមួយ ថាតើព្រឹត្តិការណ៍អ្វីដែលជំរុញឲ្យមានការធ្វើសកម្មភាពតស៊ូមតិសហគមន៍ច្រើនបំផុត។ សកម្មភាពសំខាន់ៗជាច្រើនត្រូវបានវិភាគបន្ថែមទៀតក្នុងករណីសិក្សាមួយចំនួនដោយនាំឲ្យមានការពិភាក្សាបន្ថែមទៀតចំពោះសកម្មភាពតស៊ូមតិសំខាន់ៗក្នុងរាជធានីភ្នំពេញ។

## ចំនួនរបាយការណ៍សរុប

តារាងរបាយការណ៍ឃ្លាំមើលទាំងអស់ដែលចេញដោយអង្គការសមាគមធាងត្នោតក្នុងចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦៖

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|
| មករា | ០ | ១១ | ៨ | ៨ | ២៧ |
| កុម្ភៈ | ៩ | ៧ | ៩ | ៩ | ៣៤ |
| មីនា | ១០ | ១០ | ១០ | ១១ | ៤១ |
| មេសា | ៦ | ៧ | ៦ | ៦ | ២៥ |
| ឧសភា | ៩ | ៣ | ៤ | ១១ | ២៧ |
| មិថុនា | ៩ | ៧ | ៣ | ៧ | ២៦ |
| កក្កដា | ១០ | ៦ | ៤ | ៨ | ២៨ |
| សីហា | ១ | ៥ | ៥ | ១៣ | ២៤ |
| កញ្ញា | ៣ | ១ | ៣ | ៤ | ១១ |
| តុលា | ៦ | ៣ | ១ | ៥ | ១៥ |
| វិច្ឆិកា | ៤ | ១ | ២ | ១០ | ១៧ |
| ធ្នូ | ៣ | ២ | ២ | ១១ | ១៨ |
| សរុប | ៧០ | ៦៣ | ៥៧ | ១០៣ | ២៩៣ |

## ចំនួនរបាយការណ៍សរុប៖ ការបែងចែកតាមប្រភេទ

មានរបាយការណ៍ចំនួន១៤២ ដែលត្រូវបានឃ្លាំមើលដោយអង្គការសមាគមធាងត្នោតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិដីធ្លី។ របាយការណ៍នេះជាព័ត៌មានដ៏សំខាន់លើការសិក្សាសកម្មភាពតវ៉ារបស់សហគមន៍ទាំងនេះ។ លើសពីនេះ ករណីបណ្ដឹងតុលាការប្រឆាំងនឹងសកម្មជនសិទ្ធិដីធ្លី ការតវ៉ានិងប្រមូលផ្ដុំដើម្បីគាំទ្រដល់សកម្មជនសិទ្ធិដីធ្លីដែលជាប់ពន្ធនាគារ និងរបាយការណ៍ឃ្លាំមើលយុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" ត្រូវបានលើកយកមកបញ្ចូលក្នុងករណីសិក្សាក្រោយការវិភាគរបាយការណ៍ទាំងនេះ។

| ប្រភេទ | ចំនួនរបាយការណ៍ |
|---|---|
| ការតវ៉ាបញ្ហាដីធ្លី | ១៤២ |
| បណ្ដឹងតុលាការ | ១៦ |
| ការតវ៉ាពាក់ព័ន្ធនឹងការជាប់ពន្ធនាគារ | ៥៦ |
| ថ្ងៃចន្ទពណ៌ខ្មៅ | ១៩ |
| អំពើហិង្សា | ២១ |
| ផ្សេងៗ | ៣៩ |

## ចំនួនរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាដីធ្លី

តារាងរបាយការណ៍ឃ្លាំមើលទាំងអស់ដែលចេញដោយអង្គការសមាគមជាងត្នោតចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦៖

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|
| មករា | ០ | ២ | ៤ | ៤ | ១០ |
| កុម្ភៈ | ៣ | ១ | ១ | ៨ | ១៣ |
| មីនា | ២ | ៤ | ៥ | ៨ | ១៩ |
| មេសា | ៤ | ៤ | ៥ | ៥ | ១៨ |
| ឧសភា | ៧ | ១ | ៤ | ៥ | ១៧ |
| មិថុនា | ២ | ៤ | ២ | ៤ | ១២ |
| កក្កដា | ៧ | ៣ | ៤ | ២ | ១៦ |
| សីហា | ០ | ៥ | ២ | ៨ | ១៥ |
| កញ្ញា | ០ | ១ | ២ | ០ | ៣ |
| តុលា | ១ | ២ | ១ | ២ | ៦ |
| វិច្ឆិកា | ១ | ០ | ១ | ២ | ៤ |
| ធ្នូ | ៣ | ០ | ២ | ៤ | ៩ |
| សរុប | ៣០ | ២៧ | ៣៣ | ៥២ | ១៤២ |

ចំនួនអ្នកចូលរួមក្នុងសកម្មភាពតស៊ូមតិនីមួយៗមានជាមធ្យមប្រមាណ ៧២នាក់ ដោយចំនួនភាគច្រើន (៦៥ដង) នៃសកម្មភាពទាំងនេះពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់បឹងកក់។ ការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋធំបំផុតពាក់ព័ន្ធនឹងការអភិវឌ្ឍនេះធ្វើឡើងនៅតំបន់បឹងកក់ដោយមានអ្នកចូលរួមប្រមាណ ៥០០នាក់ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ នៅលើខ្សាច់តំបន់បឹងកក់ក្នុងរាជធានីភ្នំពេញ។ អ្នកចូលរួមក្នុងការតវ៉ានោះរួមមាន សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ សហគមន៍បឹងប្រាំមកពីខេត្តបាត់ដំបង ព្រះសង្ឃ អ្នកបើករ៉ឺម៉កទេសចរណ៍ (កង់បី) សកម្មជនសិទ្ធិមនុស្ស និងអ្នកចូលរួមផ្សេងទៀត។

សកម្មភាពតស៊ូមតិរបស់សហគមន៍ពាក់ព័ន្ធនឹងរឿងដីធ្លីដែលមានអ្នកចូលរួមតិចបំផុតគឺនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ដែលពេលនោះស្ត្រីម្នាក់តំណាងឱ្យប្រជាពលរដ្ឋចំនួនពីរគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារការពង្រីកផ្លូវនៅក្នុងភូមិព្រែកព្នៅបានចេញមុខតវ៉ានៅមុខរដ្ឋសភា។ លោកស្រីបានដាក់ញត្តិស្នើសុំការអន្តរាគមន៍ពីសម្តេចពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាជាតិ បន្ទាប់ពីលំនៅដ្ឋានរបស់គាត់ត្រូវបានអាជ្ញាធរឈូសឆាយដោយមិនបានផ្តល់សំណងសមរម្យ។

## ចំនួនរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាដីធ្លី៖ ការបែងចែកតាមឆ្នាំ

ក្រាហ្វិចខាងក្រោមនេះបង្ហាញពីចំនួនរបាយការណ៍ប្រចាំឆ្នាំ




នៅក្នុងឆ្នាំ២០១៦ របាយការណ៍មានការកើនឡើងបើធៀបទៅនឹងឆ្នាំមុនៗ។ នេះគឺដោយសារតែជម្លោះដីធ្លីកំពុងបន្តកើតមានក្នុងសហគមន៍មួយចំនួនដូចជា សហគមន៍បឹងកក់ សហគមន៍បុរីកីឡា និងសហគមន៍ព្រលានយន្តហោះជាដើម។ នៅពេលដែលជម្លោះទាំងនេះមិនទាន់មានដំណោះស្រាយសមរម្យ សហគមន៍ក៏នៅតែបន្តការតវ៉ាដែរ។ បញ្ហានេះត្រូវបានរួមផ្សំគ្នាជាមួយនឹងជម្លោះថ្មីៗដែលកំពុងកើនឡើងក្នុងរាជធានីភ្នំពេញ និងការផ្តន្ទាទោសសកម្មជនសំខាន់ៗមួយចំនួនដូចជាអ្នកស្រី ទេព វន្នី (សូមមើលករណីសិក្សាថ្ងៃចន្ទពណ៌ខ្មៅ) ជាដើម។ រីឯមូលហេតុមួយដែលនាំឲ្យមានការធ្លាក់ចុះនៃរបាយការណ៍ក្នុងឆ្នាំ២០១៤ គឺដោយសារការបង្ក្រាបរបស់រដ្ឋាភិបាលទៅការតវ៉ា និងការប្រមូលផ្តុំនានា។ តាមរយៈទិន្នន័យនេះ យើងអាចសន្និដ្ឋានបានថា នេះអាចជាកត្តាដែលជំរុញឱ្យមានការកើនឡើងក្នុងរយៈពេលពីរឆ្នាំបន្ទាប់ ដោយសហគមន៍ឆ្លើយតបទៅនឹងការបង្ក្រាបតាមរយៈការបង្កើនសកម្មភាពតស៊ូមតិរបស់ខ្លួន។



*សកម្មជនសិទ្ធិលំនៅដ្ឋានប្រារព្ធទិវាលំនៅដ្ឋានពិភពលោកដោយដង្ហែក្បួនពីអតីតសហគមន៍ដីក្រហមមកកាន់រដ្ឋសភាជាតិថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ (ចម្ងាយផ្លូវប្រហែល ០.៥ គីឡូម៉ែត្រ) ដើម្បីដាក់ញត្តិទាមទារឲ្យមានដំណោះស្រាយបញ្ហាលំនៅដ្ឋានក្នុងទីក្រុង។*

*ប្រភព៖ អង្គការសមាគមធាងត្នោត ឆ្នាំ២០១៥*

## ករណីសិក្សាៈ សហគមន៍បឹងកក់

ក្រោយពីរបបខ្មែរក្រហម និងមុនពេលមានការអភិវឌ្ឍតំបន់បឹងកក់ដែលមានទីតាំងស្ថិតនៅក្នុងខណ្ឌទួលគោកក្នុងរាជធានីភ្នំពេញមានប្រជាពលរដ្ឋរស់នៅតំបន់នេះប្រមាណ ៤,០០០ គ្រួសារ (ប្រហែល២០,០០០ នាក់)។[20] បឹងនេះមានសារប្រយោជន៍ណាស់ក្នុងការផ្តល់ឱកាសការងារសម្រាប់ប្រជាពលរដ្ឋតាមរយៈការប្រកបរបរនេសាទត្រី និងការប្រមូលផលពីដំណាំផ្សេងៗក្នុងទឹកយកមកលក់នៅតាមទីផ្សារដែលនេះជាប្រភពនៃប្រាក់ចំណូលមួយ ឬប្រើប្រាស់បឹងនោះសម្រាប់ការចិញ្ចឹមជីវិតផ្ទាល់ខ្លួន។ លើសពីនេះទៀត ភាពល្បីល្បាញរបស់បឹងនេះបានទាក់ទាញភ្ញៀវទេសចរណ៍ ហើយបានជួយបង្កើនប្រាក់ចំណូលដល់អ្នកលក់ម្ហូបអាហារ និងភេសជ្ជៈក្នុងតំបន់នោះ ហើយតម្រូវការផ្ទះសំណាក់ ភោជនីយដ្ឋាន និងហាងទំនិញក្នុងតំបន់នោះក៏មានការកើនឡើងផងដែរ។[21]

ជម្លោះដីធ្លីនៅតំបន់បឹងកក់មានភាពចម្រូងចម្រាសខ្លាំងនៅក្នុងប្រទេសកម្ពុជា ដោយសារប្រជាពលរដ្ឋចំនួន ២,៦៨៨គ្រួសារត្រូវបានបណ្តេញចេញដោយបង្ខំពីលំនៅដ្ឋាន និងដីធ្លីរបស់ពួកគេក្នុងអំឡុងឆ្នាំ២០០៨-២០១១។[22] ជម្លោះនេះបានចាប់ផ្តើមក្នុងឆ្នាំ២០០៧ ហើយខួបលើកទី១០នៃជម្លោះនេះ ទើបតែកន្លងហួសកាលពីពេលថ្មីៗនេះ ចាប់តាំងពីមានការប្រកាសអភិវឌ្ឍន៍រួមគ្នាដោយសាលារាជធានីភ្នំពេញ និងក្រុមហ៊ុនអភិវឌ្ឍន៍ស៊ូកាគូ។[23]

ការជួលដីទំហំ ១៣៣ ហិកតា និងតំបន់ជុំវិញបឹងនេះក្នុងរយៈពេល ៩៩ឆ្នាំ ត្រូវបានចុះហត្ថលេខាដោយក្រុមហ៊ុនស៊ូកាគូ[24] ដោយមានបំណងប្រែក្លាយទីតាំងនេះឱ្យទៅជាទីក្រុងរណបមួយ។ បន្ទាប់ពីបានផ្ទេរពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋក្នុងឆ្នាំ២០០៨ ដែលអនុញ្ញាតឱ្យមានការលក់ដូរបាន។ ក្រុមហ៊ុនស៊ូកាគូចាប់ផ្តើមបូមខ្សាច់លុបបឹង ហើយបានចាក់បំពេញបឹងទាំងស្រុងនៅឆ្នាំ២០១២។[25] ប៉ុន្តែ ក្នុងរយៈពេលជាង១០ឆ្នាំមកនេះ ដីនោះត្រូវបានអភិវឌ្ឍន៍តែមួយផ្នែកប៉ុណ្ណោះ ដែលនាំឲ្យមានការងឿងឆ្ងល់ពីសំណាក់គ្រួសារដែលទទួលរងការបណ្តេញដោយបង្ខំ ហើយក្រុមគ្រួសារនៃតំបន់បឹងកក់មិនបានមើលឃើញថាការអភិវឌ្ឍនេះផ្តល់អត្ថប្រយោជន៍ដល់ទីក្រុងតាមការសន្យាឡើយ។[26] ប្រការទាំងនេះ រួមនឹងការតស៊ូទាមទារសំណងសមរម្យសម្រាប់គ្រួសារដែលត្រូវបានបណ្តេញចេញបានក្លាយជាកត្តាសំខាន់ដែលនាំឲ្យមានសកម្មភាពតស៊ូមតិរបស់សហគមន៍។

ចាប់តាំងពីការប្រកាសឲ្យមានការអភិវឌ្ឍនៅតំបន់នេះ សហគមន៍ដែលរងផលប៉ះពាល់បានប្រើប្រាស់សិទ្ធិរបស់ពួកគាត់ដើម្បីតវ៉ា និងទាមទារសំណងសមរម្យចំពោះការខាតបង់របស់ពួកគេ។ សកម្មភាពតស៊ូមតិសហគមន៍ភាគច្រើនដែលបានឃ្លាំមើលដោយអង្គការសមាគមធាងត្នោត គឺជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់បឹងកក់។ ក្នុងចំណោមរបាយការណ៍ឃ្លាំមើលពាក់ព័ន្ធនឹងបញ្ហាដីធ្លីចំនួន១៤២ មានរបាយការណ៍ចំនួន៦៥ ដែលពាក់ព័ន្ធនឹងជម្លោះដីធ្លីនៅតំបន់នេះ។

ធនាគារពិភពលោកដែលជាស្ថាប័នអភិវឌ្ឍន៍ និងជំនួយហិរញ្ញវត្ថុអន្តរជាតិមានបញ្ហាជាមួយការអភិវឌ្ឍតំបន់បឹងកក់ និងការធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់ដល់ប្រជាពលរដ្ឋ។ ធនាគារនេះបានចាប់ផ្តើមផ្តល់មូលនិធិដល់

គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងគ្រប់គ្រងគម្រោងរដ្ឋបាល និងគ្រប់គ្រងដីធ្លី[27] ក្នុងគោលបំណងជួយអ្នកដែលរស់នៅតំបន់បឹងកក់ទទួលបាននូវសិទ្ធិរស់នៅស្របច្បាប់លើដីតំបន់នោះ ប៉ុន្តែដោយដំណើរការមានការយឺតយ៉ាវក្រោយមក រដ្ឋាភិបាលកម្ពុជាបានលុបចោលគម្រោងនោះវិញក្នុងឆ្នាំ២០០៩ ដែលជាហេតុនាំឲ្យប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ត្រូវការពារសិទ្ធិរបស់ពួកគេដោយខ្លួនឯង។ ជាការឆ្លើយតប ធនាគារពិភពលោកបានបង្អាកការផ្តល់ប្រាក់កម្ចីដល់ប្រទេសកម្ពុជា រហូតទាល់តែមានដំណោះស្រាយសមរម្យជូនប្រជាពលរដ្ឋនៅតំបន់បឹងកក់។[28] តាមរយៈការចេញរបាយការណ៍របស់ខ្លួនមួយស្តីពីបញ្ហានេះ ធនាគារពិភពលោកបានទទួលស្គាល់ពីការបរាជ័យរបស់ខ្លួនដែលមិនអាចជួយដល់គ្រួសារដែលទទួលរងផលប៉ះពាល់ទាំងនេះបាន។

## ចំនួនរបាយការណ៍ឃ្លាំមើលករណីសហគមន៍បឹងកក់




កាលពីខែមេសាឆ្នាំនេះ សាលារាជធានីភ្នំពេញបានប្រកាសថាពួកគេបាន "ដោះស្រាយបញ្ចប់រួចរាល់...ចំពោះជម្លោះដីធ្លីនៅតំបន់បឹងកក់"[29] បើទោះបីជាពុំទាន់មានការព្រមព្រៀងគ្នាលើដំណោះស្រាយសម្រាប់ប្រជាពលរដ្ឋ ៧ គ្រួសារទៀតដែលពុំទាន់ទទួលយកសំណងនៅឡើយ។ អភិបាលរងរាជធានីភ្នំពេញ លោក ឃួង ស្រេង បានព្រមានថា ប្រសិនបើសហគមន៍នៅតែបន្តការតវ៉ា ហើយ "ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ" នោះអាជ្ញាធរនឹងចាត់វិធានការតាមផ្លូវច្បាប់។[30]

## ករណីសិក្សា៖ អ្នកស្រី យ៉ោម បុប្ផា

អ្នកស្រី យ៉ោម បុប្ផា គឺជាសកម្មជនបឹងកក់ដ៏លេចធ្លោម្នាក់ដែលអាជ្ញាធរបានកំណត់មុខសញ្ញា បន្ទាប់ពីអ្នកស្រីបានធ្វើសកម្មភាពតស៊ូមតិសហគមន៍ជាមួយអ្នកសហគមន៍បឹងកក់នៅពេលដែលស្ត្រីបឹងកកក់ចំនួន ១៣នាក់ត្រូវបានចាប់ខ្លួនដោយហិង្សាក្នុងអំឡុងពេលនៃការតវ៉ាដោយសន្តិវិធី។[31] អង្គការលីកាដូរាយការណ៍ថាបន្ទាប់ពី អ្នកស្រី បុប្ផា ដើរតួនាទីក្នុងសកម្មភាពតវ៉ានេះ អ្នកស្រីត្រូវបានប៉ូលីសព្រមានថា អ្នកស្រីស្ថិតនៅក្នុងបញ្ជីខ្មៅ ហើយអ្នកស្រីអាចនឹងមានបញ្ហាក្នុងពេលឆាប់ៗ។[32]

ក្នុងអំឡុងពេលនៃយុទ្ធនាការទាមទារឲ្យមានការដោះលែងសកម្មជនបឹងកក់ទាំង ១៣នាក់ អ្នកស្រីបុប្ផា ត្រូវបានអាជ្ញាធរកំណត់ជាមុខសញ្ញា ដោយសារតែភាពសកម្មរបស់គាត់ក្នុងការតវ៉ាជាមួយសហគមន៍បឹងកក់ ហើយអ្នកស្រីត្រូវបានចាប់ខ្លួននៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ ពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តទៅលើអ្នកបើកបរម៉ូតូពីរនាក់។ មិនមានភ័ស្តុតាងដាក់បន្ទុកក្នុងសវនការជំនុំជម្រះរឿងក្តីនេះទេ[33] ប៉ុន្តែដោយសារតែជម្លោះរ៉ាំរ៉ៃនៅតំបន់បឹងកក់ ប្រជាពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលជឿថា មូលហេតុពិតប្រាកដនៅពីក្រោយការចាប់ខ្លួនអ្នកស្រី យ៉ោម បុប្ផា គឺដោយសារតែអ្នកស្រីជាសកម្មជនសិទ្ធិមនុស្ស ហើយដែលប្រព័ន្ធតុលាការត្រូវបានគេចោទថាជាស្ថាប័នពុករលួយដោយព្យាយាមបំបិទមាត់អ្នកស្រី។ អង្គការលីកាដូលើកឡើងថា "អាជ្ញាធរកម្ពុជាមានប្រវត្តិយូរអង្វែងមកហើយក្នុងការបំបិទមាត់អ្នករិះគន់ និងអ្នកដែលគេចាត់ទុកថាបង្កបញ្ហាតាមរយៈការប្រឌិតបទចោទប្រកាន់ធ្វើឡើងដោយប្រព័ន្ធតុលាការដែលមានភាពមិនប្រក្រតី និងប្រកាន់បក្សពួក"។[34]

ទោះជាមិនមានភ័ស្តុតាងគ្រប់គ្រាន់ក៏ដោយ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ អ្នកស្រី យ៉ោម បុប្ផា ត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ៣ឆ្នាំ ហើយបង្គាប់ឱ្យបង់ប្រាក់សងជម្ងឺចិត្តចំនួន ១៥,០០០ ដុល្លារដល់ជនរងគ្រោះក្នុងបទល្មើសដែលអ្នកស្រីត្រូវបានចោទប្រកាន់ថាបានរៀបចំទុកជាមុន។[35] ប៉ុន្តែក្រោយពីមានយុទ្ធនាការអន្តរជាតិមួយដឹកនាំដោយអង្គការលើកលែងទោសអន្តរជាតិ ដែលពេលនោះ លិខិតប្រហែល ២៥៣,០០០ ច្បាប់ត្រូវបានប្រគល់ទៅឲ្យអាជ្ញាធរកម្ពុជាដើម្បីសំដែងការគាំទ្រទាមទារឲ្យមានការដោះលែងអ្នកស្រីឲ្យមានសេរីភាពឡើងវិញ[36]។ ក្រោយមក តុលាការកំពូលបានបញ្ជាឱ្យបើកសវនាការជំនុំជម្រះឡើងវិញ ហើយអ្នកស្រីបុប្ផាត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។[37] នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ សវនាការជំនុំជម្រះឡើងវិញបានរកឃើញជាថ្មីម្តងទៀតថាអ្នកស្រីមានពិរុទ្ធភាពក្នុងបទល្មើសរៀបចំទុកជាមុនក្នុងការវាយប្រហារលើមនុស្សពីរនាក់ក្នុងឆ្នាំ២០១២ ហើយអ្នកស្រីត្រូវបានកាត់ឲ្យជាប់ទោសនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦។ ទោះបីជាអ្នកស្រីត្រូវបានតុលាការរកឃើញថាមានទោសក៏ដោយ ក៏ការអនុវត្តទោសដែលនៅសល់របស់អ្នកស្រីត្រូវបានព្យួរ ប៉ុន្តែអ្នកស្រីត្រូវបានបង្គាប់ឱ្យបង់ប្រាក់សំណងចំនួន ២,៥០០ ដុល្លារជូនដល់ជនរងគ្រោះ។[38]

ករណីរបស់អ្នកស្រី យ៉ោម បុប្ផា គឺជាករណីបុគ្គលដំបូងគេដែលអង្គការសមាគមធាងត្នោតឃ្លាំមើលញឹកញាប់។ របាយការណ៍ជាច្រើនដែលពាក់ព័ន្ធនឹងករណីអ្នកស្រីបុប្ផា គឺជារបាយការណ៍អំពីការប្រមូលផ្តុំរបស់សហគមន៍នៅពេលអ្នកស្រីត្រូវបាននាំខ្លួនទៅតុលាការ ឬការតវ៉ាឲ្យមានការដោះលែងអ្នកស្រីពីពន្ធនាគារ។ ក្នុងរបាយការណ៍ចំនួន ២៨ ដែលពាក់ព័ន្ធនឹងករណីអ្នកស្រី បុប្ផា មានអ្នកចូលរួមជាមធ្យមប្រមាណ ៨២នាក់ ដែលភាគច្រើនមកពីសហគមន៍បឹងកក់ សហគមន៍បុរីកីឡា និងសហគមន៍ថ្មគោលបានប្រមូលផ្តុំដើម្បីគាំទ្រអ្នកស្រី។ ការប្រមូលផ្តុំគ្នាធំបំផុតដែលអំពាវនាវឱ្យមានការដោះលែងអ្នកស្រី បុប្ផា មានការចូលរួមពីប្រជាពលរដ្ឋចំនួន ៤០០នាក់ ធ្វើឡើងនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ នៅខាងក្រៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញ។

## ករណីសិក្សា៖ ថ្ងៃចន្ទពណ៌ខ្មៅ

យុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" បានធ្វើឡើងក្នុងគោលបំណងឆ្លើយតបទៅនឹងការចាប់ខ្លួនមន្ត្រីសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (អាដហុក) ចំនួន ៤រូប និងមន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ១រូបទៀត។ កាលពីដើមខែឧសភា ឆ្នាំ២០១៦ ពួកគេទទួលរងការចោទប្រកាន់លក្ខណៈនយោបាយ ថាបានសូកប៉ាន់សាក្សីក្នុងសំណុំរឿងអាស្រូវផ្លូវភេទពាក់ព័ន្ធនឹងមេដឹកនាំគណបក្សប្រឆាំងដ៏ល្បីល្បាញគឺលោក កឹម សុខា។[39] ជនជាប់ចោទនៅតែអះអាងថាគ្រាន់តែ "ផ្តល់ជំនួយផ្នែកច្បាប់ដល់ស្ត្រីនោះ ដែលនេះជាផ្នែកមួយនៃការងារតស៊ូមតិរបស់ខ្លួន"[40] ប៉ុន្តែពួកគាត់នៅតែត្រូវបានបន្តឃុំខ្លួនជាបណ្តោះអាសន្ន។

យុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" បានផ្អាកសកម្មភាពរយៈពេលពីរសប្តាហ៍ក្នុងខែកញ្ញាឆ្នាំ២០១៦ បន្ទាប់ពីមានព័ត៌មានថា រដ្ឋាភិបាលគ្រោងនឹងដោះលែងសកម្មជនដែលកំពុងជាប់ពន្ធនាគារ។ ប៉ុន្តែ ក្រោយពីមិនឃើញមានការដោះលែង ក្រុមអ្នកតវ៉ាបានបន្តធ្វើយុទ្ធនាការនេះទៀត[41]។ យុទ្ធនាការនេះបន្តធ្វើនៅទូទាំងរាជធានីភ្នំពេញ ហើយវាត្រូវបានរំពឹងទុកថា (ដោយអង្គការសមាគមផងគ្នោត) នឹងបន្តធ្វើរហូតទាល់តែសកម្មជនដែលជាប់ឃុំឃាំងដោយមិនត្រឹមត្រូវទាំងអស់ត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ។

### ចំនួនរបាយការណ៍ឃ្លាំមើលយុទ្ធនាការថ្ងៃចន្ទពណ៌ខ្មៅ



## ករណីបុគ្គលនៃ "យុទ្ធនាការថ្ងៃចន្ទពណ៌ខ្មៅ"៖ អ្នកស្រី ទេព វន្នី

អ្នកស្រី ទេព វន្នី ជាអ្នករស់នៅក្នុងតំបន់បឹងកក់ហើយបានក្លាយជាសកម្មជនសិទ្ធិដីធ្លីដ៏លេចធ្លោក្នុងអំឡុងពេលជម្លោះតំបន់បឹងកក់កំពុងបន្តកើតមាន។ អ្នកស្រី ទេព វន្នី ដើរតួយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំអ្នកសហគមន៍បឹងកក់ប្រឆាំងនឹងការអភិវឌ្ឍនៅតំបន់នោះដែលក្រោយមកត្រូវបានបណ្តេញចេញដោយបង្ខំ។

ពាក់ព័ន្ធនឹងរបាយការណ៍ឃ្លាំមើលដែលផ្តោតលើករណីអ្នកស្រី វន្នី គឺជាករណីថ្មីនិងលេចធ្លោបំផុតដោយមានរបាយការណ៍ចំនួន៩ ត្រឹមចន្លោះខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៦តែប៉ុណ្ណោះ។ ការអំពាវនាវឲ្យដោះលែងអ្នកស្រី វន្នី ត្រូវបានធ្វើឡើងក្នុងអំឡុងយុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" ដោយសហគមន៍ដែលលេចធ្លោចំនួនពីរគឺសហគមន៍បឹងកក់ និងសហគមន៍បុរីកីឡាដែលគាំទ្រដល់អ្នកស្រី។ ក្រុមសកម្មជនដីធ្លីនិងសិទ្ធិមនុស្សបន្តទាមទារឲ្យមានការដោះលែងអ្នកស្រី វន្នី ពីការដាក់ពន្ធនាគារដោយមិនត្រឹមត្រូវ។

អ្នកស្រី ទេព វន្នី ត្រូវបានចាប់ខ្លួនដំណាលគ្នាជាមួយនឹងអ្នកស្រី បូវ សោភា នៅពេលពួកគេធ្វើយុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" លើកទី១៥ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦។ អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទ "ញុះញង់" ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា (មាត្រា៤៩៥) ប៉ុន្តែដោយសារមិនមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកក្នុងបទចោទប្រកាន់នេះ បទចោទប្រកាន់ត្រូវបានប្តូរទៅជា "ការប្រមាថមន្ត្រីសាធារណៈ" ហើយពួកគាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធធនាគាររយៈពេល ៦ថ្ងៃ។ អ្នកស្រី បូវ សោភា ត្រូវបានដោះលែងវិញបន្ទាប់ពីរយៈពេល ៦ថ្ងៃ ប៉ុន្តែបទចោទប្រកាន់បន្ថែមលើអ្នកស្រី ទេព វន្នី ដែលបណ្តាលមកពីការប្រមូលផ្តុំនៅខាងក្រៅផ្ទះរបស់នាយករដ្ឋមន្ត្រីហ៊ុន សែន នៅភ្នំពេញ កាលពី៣ឆ្នាំមុន នៅក្នុងខែមីនា ឆ្នាំ២០១៣ ដែលការតវ៉ានោះគឺដើម្បីអំពាវនាវឱ្យដោះលែងអ្នកស្រី យ៉ោម បុប្ផា ដែលមានន័យថាករណីរបស់អ្នកស្រី ទេព វន្នី ត្រូវបានយកមកអនុវត្តន៍ឡើងវិញ។[42] នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ អ្នកស្រី ទេព វន្នី ត្រូវបានចោទប្រកាន់ពីបទ "បង្កហិង្សាដោយចេនាមានស្ថានទម្ងន់ទោស"[43] ហើយត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ និង៦ខែ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧។ នៅពេលសរសេររបាយការណ៍នេះ (ខែឧសភា ឆ្នាំ២០១៧) អ្នកស្រី ទេព វន្នី ត្រូវបានឃុំខ្លួនលើសពីរយៈពេល ២៨៧ ថ្ងៃ មកហើយ គិតចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ មក។

សកម្មជនដទៃទៀត និងសហគមន៍ជាតិនិងអន្តរជាតិនានាបានថ្កោលទោសចំពោះការកាត់ទោសអ្នកស្រី ទេព វន្នី។ សកម្មភាពរបស់អាជ្ញាធរដែលរងការចោទប្រកាន់ថាពុករលួយបានជំរុញឱ្យគេជឿថា ការឃុំឃាំងអ្នកស្រី ទេព វន្នី គឺជាការប៉ុនប៉ងរារាំងអ្នកស្រីមិនឲ្យធ្វើការតស៊ូមតិតទៅទៀត ដែលប្រការនេះត្រូវបានអង្គការសេរីភាពសំដែងមតិសកលសរសេរថា "ការដែលអាជ្ញាធរកំណត់មុខសញ្ញាម្តងហើយម្តងទៀតលើអ្នកស្រីទេព វន្នី នោះ និងការបរាជ័យក្នុងការបើកសវនាការឱ្យមានប្រសិទ្ធភាពលើបទចោទប្រកាន់អ្នកស្រី មានន័យថាអាជ្ញាធរបានប្រើប្រាស់ច្បាប់មកធ្វើជាមធ្យោបាយបំបិទមាត់អ្នកស្រី"។[44]




*អ្នកស្រី ទេព វន្នី ចូលរួមការតវ៉ាដោយសន្តិវិធីទាមទារឲ្យមានការដោះលែងសកម្មជន*
*សហគមន៍បឹងកក់អ្នកស្រី យ៉ោម បុប្ផា នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤*
*ប្រភព៖ អង្គការសមាគមធាងត្នោត ឆ្នាំ២០១៤*




*អ្នកស្រី ទេព វន្នី និងសកម្មជនដទៃទៀតជួបជុំគ្នាមុខរដ្ឋសភាជាតិក្នុងអំឡុងពេល*
*យុទ្ធនាការតវ៉ាចំពោះជំទាស់នឹងការចាក់ដីលុបបឹងកក់និង*
*ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦*

*ប្រភព៖ អង្គការសមាគមធាងត្នោត ឆ្នាំ២០១៦*

## សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍរាជធានីភ្នំពេញនឹងនៅតែបន្ត បើទោះបីជាមានសកម្មភាពតស៊ូមតិធ្វើឡើងដោយសហគមន៍នៅទូទាំងក្នុងទីក្រុងក៏ដោយ ប៉ុន្តែការផ្តល់សំណងសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយការអភិវឌ្ឍនោះ នៅតែជាបញ្ហា ហើយការតវ៉ានឹងបន្តរហូតទាល់តែការផ្តល់យុត្តិធម៌ដល់សហគមន៍ដូចទៅនឹងប្រជាពលរដ្ឋនៅរាជធានីភ្នំពេញដទៃទៀតដែរ។

សម្រាប់ប្រជាពលរដ្ឋ ការអភិវឌ្ឍទាំងក្នុងពេលបច្ចុប្បន្ននិងពេលអនាគតនៅតែជាកង្វល់ដោយសារការមិនគោរពសិទ្ធិមនុស្ស និងសិទ្ធិលំនៅដ្ឋានដែលកំពុងកើតឡើងក្នុងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០១៦ អង្គការសមាគមជាងត្នោតរកឃើញថាអ្នកដែលទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍ ជាទូទៅគាំទ្រចំពោះការអភិវឌ្ឍ ហើយយល់ពីអត្ថប្រយោជន៍ដែលការអភិវឌ្ឍនឹងនាំមកសម្រាប់ទីក្រុង និងប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងនោះ។[45] អ្វីដែលពួកគាត់ចង់បានគឺសំណងសមរម្យ និងមានការដោះស្រាយនៅពេលប្រឈមនឹងការបណ្តេញចេញដោយបង្ខំ និងបន្តអនុវត្តន៍សិទ្ធិរបស់ពួកគាត់ក្នុងការតវ៉ា និងប្រយុទ្ធប្រឆាំងដើម្បីការពារសិទ្ធិពេញលេញរបស់ពួកគាត់ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ជាការសោកស្តាយ ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធយុត្តិធម៌កម្ពុជានៅតែបន្តរាំងស្ទះដល់សកម្មភាពតស៊ូមតិរបស់សហគមន៍ដោយអាជ្ញាធរដែលគេចោទថាអំពើពុករលួយ រារាំងដល់ដំណើរការកាត់ក្តីដោយយុត្តិធម៌សម្រាប់សកម្មជនសិទ្ធិមនុស្ស និងដីធ្លី។ លើសពីនេះទៅទៀត ការភ័យខ្លាចចំពោះអំពើហិង្សាលើរូបរាងកាយ និងការកាត់ឲ្យជាប់ទោសពីបទព្រហ្មទណ្ឌលើអ្នកតវ៉ាការពារសិទ្ធិរបស់ខ្លួនគឺជារឿងដែលគេដឹងជាទូទៅ ហើយវានឹងនៅបន្តគំរាមកំហែងដល់អ្នកដែលចូលរួមក្នុងសកម្មភាពតស៊ូមតិរហូតទាល់តែការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្នត្រូវបានពិនិត្យមើលឡើងវិញ។

## អនុសាសន៍

### សហគមន៍រងផលប៉ះពាល់

អ្នកទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍដោយអយុត្តិធម៌គួរតែបន្តអនុវត្តន៍សិទ្ធិរបស់ខ្លួនដោយសន្តិវិធី និងអំពាវនាវឱ្យមានការដោះស្រាយដោយសមរម្យនិងយុត្តិធម៌ពីអាជ្ញាធរមានសមត្ថកិច្ច។ ប៉ុន្តែ ពួកគេគួរតែធ្វើសកម្មភាពដោយគោរពនិងស្របតាមច្បាប់ពាក់ព័ន្ធនានាឲ្យបានខ្ជាប់ខ្ជួន ហើយស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានដែលអាចទុកចិត្តបានដើម្បីជួយតាមដានព្រឹត្តិការណ៍ និងផ្តល់ការការពារសន្តិសុខប្រឆាំងនឹងអំពើហិង្សាដែលអាចកើតមាន។

### អាជ្ញាធរពាក់ព័ន្ធ

ការរំខានសកម្មភាពតស៊ូមតិរបស់សហគមន៍ និងសកម្មជនសិទ្ធិដីធ្លីដោយការគំរាមកំហែងដោយបង្កហិង្សា ការចាប់ដាក់ពន្ធនាគារ ការសងសំណងមិនសមរម្យ ឬប្រការផ្សេងទៀតនឹងបន្តជំរុញឲ្យមានការមិនពេញចិត្តនិងកំហឹងពីអ្នកដែលរងផលប៉ះពាល់ពីការអភិវឌ្ឍ។ ផ្ទុយមកវិញ អាជ្ញាធរគួរតែស្វែងរកដំណោះស្រាយសមរម្យណាមួយសម្រាប់គោលការណ៍ផ្តល់សំណងនៅពេលមានការបណ្តេញចេញដោយបង្ខំ ហើយត្រូវមានប្រព័ន្ធតុលាការ

ប្រកបដោយភាពយុត្តិធម៌ដើម្បីជួយទប់ស្កាត់ការរីកសាយនៃជម្លោះបច្ចុប្បន្ន និងការកើតមានជម្លោះថ្មីទៀត។ ប្រការនេះចាំបាច់ត្រូវទាមទារឲ្យមានការចូលរួមគ្រប់គ្រាន់ពីអាជ្ញាធរ និងអ្នកដែលរងផលប៉ះពាល់។

## អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ

វាមានសារៈសំខាន់ណាស់សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងអន្តរជាតិបន្តរាយការណ៍ពីសកម្មភាពតស៊ូមតិរបស់សហគមន៍ក្នុងរាជធានីភ្នំពេញ ហើយផ្តល់នូវការគាំទ្រដល់អ្នកដែលត្រូវការជំនួយផ្សេងៗតាមដែលអាចធ្វើទៅបាន។ តាមរយៈការសម្របសម្រួលការពិភាក្សា និងការលើកកម្ពស់ការយល់ដឹងលើបញ្ហាដីធ្លី និងសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធអាចជំរុញទឹកចិត្តឲ្យមានការធ្វើសកម្មភាពតស៊ូមតិ និងជំរុញឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

# ឯកសារយោង

[1] CDC (2017). Investment Trend « The Council for the Development of Cambodia (CDC). Available at: http://www.cambodiainvestment.gov.kh/investment-enviroment/investment-trend.html
[2] Phnompenh.gov.kh. (2017). Facts | Phnom Penh Capital Hall. Available at: http://phnompenh.gov.kh/en/phnom-penh-city/facts/
[3] Statistics Bureau Japan (2008). Population Projections for Cambodia, 2008-2030. pp.1-28. Available at: http://www.stat.go.jp/info/meetings/cambodia/pdf/rp12_ch10.pdf
[4] Sahmakum Teang Tnaut (2016). Promises Kept? A study on the Development of 77 Eviction Sites in Phnom Penh. Phnom Penh: Sahmakum Teang Tnaut. Available at: http://teangtnaut.org/promises-kept-study-development-77-eviction-sites-phnom-penh/?lang=en
[5] Sahmakum Teang Tnaut (2016). Promises Kept? A study on the Development of 77 Eviction Sites in Phnom Penh. Phnom Penh: Sahmakum Teang Tnaut. Available at: http://teangtnaut.org/promises-kept-study-development-77-eviction-sites-phnom-penh/?lang=en
[6] Sotheary, P. (2015). Titling scheme ‘deeply flawed’. The Phnom Penh Post. Available at: http://www.phnompenhpost.com/national/titling-scheme-deeply-flawed
[7] Sotheary, P. (2015). Titling scheme ‘deeply flawed’. The Phnom Penh Post. Available at: http://www.phnompenhpost.com/national/titling-scheme-deeply-flawed
[8] Human Rights Watch. (2017). Cambodia. Available at: https://www.hrw.org/world-report/2017/country-chapters/cambodia
[9] Cambodia.org. (2017). 1991 Paris Peace Agreements - Government, Constitution, National Anthem and Facts of Cambodia Cambodian Information Center. Available at: http://www.cambodia.org/facts/?page=1991+Paris+Peace+Agreements
[10] Law on Peaceful Demonstration. Article 4. p.2. Available at: https://cambodia.ohchr.org/sites/default/files/Law_on_peaceful_demonstration-promulgated_Eng.pdf
[11] Un.org. Universal Declaration of Human Rights | United Nations. Available at: http://www.un.org/en/universal-declaration-human-rights/
[12] Un.org. Universal Declaration of Human Rights | United Nations. Available at: http://www.un.org/en/universal-declaration-human-rights/
[13] Cambodia.ohchr.org. (2015). Freedom of peaceful assembly and association | OHCHR. Available at: https://cambodia.ohchr.org/en/civil-society-fund-freedoms/freedom-peaceful-assembly-association
[14] LICADHO. (2007). Briefing: Restrictions on the Freedom of Assembly in Cambodia 2006. Available at: http://www.licadho-cambodia.org/reports.php?perm=101
[15] CCHR (2011). Law on Peaceful Assembly (the “Demonstration Law”). CCHR Law Classification Series. CCHR. Available at: http://cchrcambodia.org/admin/media/factsheet/factsheet/english/Law_Fact_Sheet_2_Demonstration_Law_ENG.pdf
[16] Amnesty International (2008). Cambodia: Rights Razed: Forced Evictions in Cambodia. Available at: https://www.amnesty.org/en/documents/ASA23/002/2008/en/
[17] Ibid.
[18] Ibid.
[19] Amnesty.org.uk. (2008). Cambodia: Anti-forced eviction activists silenced by the wealthy. Available at: https://www.amnesty.org.uk/press-releases/cambodia-anti-forced-eviction-activists-silenced-wealthy
[20] Inclusive Development International. (2014). CAMBODIA: BOEUNG KAK LAKE EVICTIONS. Available at: http://www.inclusivedevelopment.net/campaign/cambodia-boeung-kak-lake-evictions/
[21] De Launey, G. (2011). Cambodia lake battle: How Boeung Kak became a puddle. BBC News. Available at: http://www.bbc.com/news/business-14488100
[22] Sahmakum Teang Tnaut (2016). Promises Kept? A study on the Development of 77 Eviction Sites in Phnom Penh. Phnom Penh: Sahmakum Teang Tnaut. Available at: http://teangtnaut.org/promises-kept-study-development-77-eviction-sites-phnom-penh/?lang=en
[23] The Phnom Penh Post (2017). Boeung Kak: A Disastrous Decade. Available at: http://www.phnompenhpost.com/post-weekend/boeung-kak-disastrous-decade

[24] Titthara, M. (2010). Boeung Kak villagers call on PM to intervene in land case. The Phnom Penh Post. Retrieved from: http://www.phnompenhpost.com/national/boeung-kak-villagers-call-pm-intervene-land-case
[25] Ruom. (2012). Boeung Kak lake's eviction, Photo Reportage - Ruom Collective. Available at: http://www.ruom.net/portfolio-item/boeung-kak-lake/
[26] Sahmakum Teang Tnaut (2016). Promises Kept? A study on the Development of 77 Eviction Sites in Phnom Penh. Phnom Penh: Sahmakum Teang Tnaut. Available at: http://teangtnaut.org/promises-kept-study-development-77-eviction-sites-phnom-penh/?lang=en
[27] Inclusive Development International. (2014). CAMBODIA: BOEUNG KAK LAKE EVICTIONS. Available at: http://www.inclusivedevelopment.net/campaign/cambodia-boeung-kak-lake-evictions/
[28] De Launey, G. (2011). Cambodia lake battle: How Boeung Kak became a puddle. BBC News. Available at: http://www.bbc.com/news/business-14488100
[29] The Phnom Penh Post (2017). Boeung Kak lake dispute ‘closed’. Available at: http://www.phnompenhpost.com/national/boeung-kak-lake-dispute-closed
[30] Ibid.
[31] LICADHO (2013). Briefing Update: The Yorm Bopha Case. The Yorm Bopha Case. LICADHO. Available at: http://www.licadho-cambodia.org/reports/files/177LICADHOBriefBopha2013-English.pdf
[32] Ibid.
[33] Amnesty International Canada. (2013). Yorm Bopha set free in Cambodia. Available at: http://www.amnesty.ca/our-work/good-news/yorm-bopha-set-free-in-cambodia
[34] LICADHO (2013). Briefing Update: The Yorm Bopha Case. The Yorm Bopha Case. LICADHO. Available at: http://www.licadho-cambodia.org/reports/files/177LICADHOBriefBopha2013-English.pdf
[35] The Phnom Penh Post (2012). Boeung Kak activist gets 3 years. Available at: http://www.phnompenhpost.com/national/boeung-kak-activist-gets-3-years
[36] Global Importune. (2016). Yorm Bopha of Cambodia. Available at: http://globalimportune.org/listing/yorm-bopha-of-cambodia
[37] Front Line Defenders. (2017). Case History: Yorm Bopha. Available at: https://www.frontlinedefenders.org/en/case/case-history-yorm-bopha
[38] Activist Yorm Bopha again found guilty (2016). The Phnom Penh Post. Available at: http://www.phnompenhpost.com/national/activist-yorm-bopha-again-found-guilty
[39] Palatino, M. (2016). What's Behind Cambodia's Black Monday Campaign? The Diplomat. Available at: http://thediplomat.com/2016/06/whats-behind-cambodias-black-monday-campaign/
[40] Ibid.
[41] Radio Free Asia. (2017). Monday Turns Black Again in Cambodia as Protests Restart. Available at: http://www.rfa.org/english/news/cambodia/monday-turns-black-01092017153718.html
[42] World Organisation Against Torture. (2017). Cambodia: Ongoing judicial harassment of land rights activist Ms. Tep Vanny Available at: http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2017/01/d24192/
[43] Front Line Defenders. (2017). Tep Vanny. Available at: https://www.frontlinedefenders.org/en/profile/tep-vanny
[44] Global Freedom of Expression. (2017). Case: Tep Vanny. Available at: https://globalfreedomofexpression.columbia.edu/cases/case-tep-vanny-cambodia/
[45] Sahmakum Teang Tnaut (2016). Promises Kept? A study on the Development of 77 Eviction Sites in Phnom Penh. Phnom Penh: Sahmakum Teang Tnaut. Available at: http://teangtnaut.org/promises-kept-study-development-77-eviction-sites-phnom-penh/?lang=en